# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | **អង់គ្លេស** |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 16-Jul-2013, 16:00
CMS/CFO: Sann Rada

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ:

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្ដោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

# ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង ការដកខ្លួនរបស់ ខៀវ សំផន មិនផ្ដល់សក្ខីកម្ម និងសំណើសុំឲ្យធ្វើសេចក្ដីសន្និដ្ឋានអវិជ្ជមាន

---

**អ្នកដាក់ឯកសារ:**

សហព្រះរាជអាជ្ញា:
លោកស្រី ជា លាង
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**

អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រម Jean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្ដឹងរដ្ឋប្បវេណី:
ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**

ជនជាប់ចោទ:
នួន ជា
ខៀវ សំផន

មេធាវីការពារក្ដីជនជាប់ចោទ:
លោក សុន អរុណ
លោក Victor Koppe
លោក គង់ សំអុន
លោក Jacques VERGÈS
លោក Arthur VERCKEN
លោកស្រី Anta GUISSÉ

## I. សេចក្តីផ្តើម និងប្រវត្តិនីតិវិធី

១- ចាប់ផ្តើមនៅថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ជនជាប់ចោទ ខៀវ សំផន បានផ្តល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដោយបានឆ្លើយទៅនឹងសំណួរនានា ដែលបានសួរដោយដើមបណ្តឹងរដ្ឋប្បវេណី[1]។ ក្នុងចម្លើយតបទៅសំណើរបស់សហព្រះរាជអាជ្ញា កាលពីថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៣ ដែលថាអង្គជំនុំជម្រះរៀបចំកាលវិភាគសវនាការលើក ក្រោយសម្រាប់សួរដេញដោលជនជាប់ចោទដែលធ្វើឡើងដោយចៅក្រម សហព្រះរាជអាជ្ញា និងភាគីដទៃទៀត អង្គជំនុំជម្រះបានចេញសេចក្តីណែនាំមួយជូនដល់ជនជាប់ចោទទាំងពីរ ដើម្បីឱ្យបញ្ជាក់ពីបំណងរបស់ខ្លួនទាក់ទងទៅនឹងការផ្តល់សក្ខីកម្មនៅថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣[2]។ ដូច្នេះ ដោយសារមានពេលវេលាបន្ថែមដើម្បីប្រឹក្សាយោបល់ជាមួយនឹងមេធាវីការពារក្តីរបស់ខ្លួន កាលពីថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ ខៀវ សំផន បានបញ្ជាក់ជូនអង្គជំនុំជម្រះសាលាដំបូងថា គាត់មានបំណងបន្តផ្តល់សក្ខីកម្មតទៅទៀត ហើយថាគាត់នឹងឆ្លើយទៅនឹងសំណួរនានាពីសំណាក់ ចៅក្រម និងភាគីដទៃទៀត[3]។

២- យ៉ាងណាក៏ដោយ នៅថ្ងៃទី៨ ខែកក្កដា ឆ្នាំ២០១៣ មេធាវីការពារក្តី ខៀវ សំផន (“មេធាវីការពារក្តី”) បានជូនព័ត៌មានដល់អង្គជំនុំជម្រះសាលាដំបូង និងភាគីនានា តាមរយៈសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរថា ជនជាប់ចោទបានដកខ្លួនលែងផ្តល់សក្ខីកម្មនោះវិញហើយ (“សេចក្តីជូនដំណឹងស្តីពីការដកខ្លួន”)[4]។ សេចក្តីជូនដំណឹងស្តីពីការដកខ្លួននេះបានថ្លែងថា សេចក្តីសម្រេចរបស់ជនជាប់ចោទក្នុងការផ្លាស់ប្តូរគំនិតនេះ គឺបានសម្អាងនៅលើការបដិសេធរបស់អង្គជំនុំជម្រះ មិនអនុញ្ញាតឱ្យមានលក្ខខណ្ឌមួយចំនួនពាក់ព័ន្ធនឹងការសួរដេញដោល ខៀវ សំផន[5] ប៉ុន្តែក៏បានលើកឡើងពីបណ្តឹងដទៃ

---

[1] **E1/196.1** ប្រតិចារឹក, ២៣ ឧសភា ២០១៣, ត្រង់ទំព័រទី១៥ [មេធាវីការពារក្តី ខៀវ សំផន បញ្ជាក់ថាខ្លួននឹងឆ្លើយតបទៅនឹងសំនួររបស់ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ ចៅ នី], ទំព័រទី១៦ ត្រង់ទំព័រទី១៥ [ដើមបណ្តឹងរដ្ឋប្បវេណី សួរសំនួរទៅកាន់ ខៀវ សំផន] និង ទំព័រទី ១៧-១៨ [ខៀវ សំផន ឆ្លើយទៅនឹងសំណួររបស់ដើមបណ្តឹងរដ្ឋប្បវេណី]។ **E1/197.1** ប្រតិចារឹក, ២៧ ឧសភា ២០១៣, ត្រង់ទំព័រទី២១-៣២, ៨២-៨៥, **E1/198.1** ប្រតិចារឹក, ២៩ ឧសភា ២០១៣, ត្រង់ទំព័រទី១៨-២៤, ២៩, ៥៤-៥៥, ៨៥-៨៩, **E1/199.1** ប្រតិចារឹក, ៣០ ឧសភា ២០១៣, ត្រង់ទំព័រទី១៦-១៨, ៨០-៨៣, **E1/200.1** ប្រតិចារឹក, ៤ ខែមិថុនា ២០១៣, ត្រង់ទំព័រទី២៤-២៥, ៦៨-៧០, ១០៩-១១០។

[2] **E1/196.1** ប្រតិចារឹក, ២៣ ឧសភា ២០១៣, ត្រង់ទំព័រទី ៣៦-៣៧ [សំណើរបស់សហព្រះរាជអាជ្ញា], ទំព័រទី ៤៤-៤៧ [សំណើរបស់ជនជាប់ចោទ ស្នើសុំពេលវេលាធ្វើការប្រឹក្សាយោបល់ជាមួយក្រុមមេធាវីការពារក្តី និងសេចក្តីណែនាំរបស់អង្គជំនុំជម្រះ]។

[3] **E1/197.1** ប្រតិចារឹក, ២៧ ឧសភា ២០១៣, ត្រង់ទំព័រទី ២-៤។

[4] **E288/4** សេចក្តីសន្និដ្ឋានរបស់ក្រុមមេធាវីការពារក្តី លោក ខៀវ សំផន ពាក់ព័ន្ធនឹងការសួរដេញដោលជនជាប់ចោទ, ៨ កក្កដា ២០១៣ (“សេចក្តីជូនដំណឹងស្តីពីការដកខ្លួន”)។

[5] **E288/4** សេចក្តីជូនដំណឹងស្តីពីការដកខ្លួន, ត្រង់កថាខណ្ឌទី៧។

ទៀតមួយចំនួនផងដែរទាក់ទងទៅនឹងការទទួលបញ្ហានានា ដែលមិនពាក់ព័ន្ធគ្នាទាំងស្រុងទៅនឹងលក្ខខណ្ឌផ្សេងៗស្តីពីការសួរដេញដោលជនជាប់ចោទ[6]។ នៅថ្ងៃដែលសេចក្តីជូនដំណឹងស្តីពីការដកខ្លួនត្រូវបានជូនដំណឹងដល់ភាគីនានា សហព្រះរាជអាជ្ញាបានស្នើសុំ និងបានយល់ព្រមដោយអង្គជំនុំជម្រះសាលាដំបូង ឲ្យធ្វើការឆ្លើយតបនៅថ្ងៃបន្ទាប់ នៅក្នុងសវនាការ[7]។

៣- នៅក្នុងឱកាសនោះ សហព្រះរាជអាជ្ញាបានផ្តល់ប្រឹក្សាជូនដល់អង្គជំនុំជម្រះថា ខ្លួនបានយល់ឃើញថាមូលហេតុដែលបានបញ្ជាក់ដោយជនជាប់ចោទស្តីពីការដកខ្លួនមិនផ្តល់សក្ខីកម្មនោះថា មិនមានមូលដ្ឋានទាំងស្រុង និងជាប្រផ្នូលប្រាប់ទុកជាមុនអំពីការដាក់ចម្លើយតបនេះ[8]។ ដោយបានលើកឡើងអំពីលក្ខខណ្ឌជាក់លាក់ ដែលជនជាប់ចោទបានស្វែងរកដាក់នៅពេលសួរដេញដោលរបស់គាត់នៅក្រោយថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានកត់សម្គាល់ឃើញថា មិនមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនោះ មានមូលដ្ឋាននៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌ដែលបានទទួលស្គាល់ដោយច្បាប់ជាតិ ឬច្បាប់អន្តរជាតិនោះឡើយ។ ទោះបីជាយ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានថ្លែងថាខ្លួនបានត្រៀមរៀបចំដាក់លក្ខខណ្ឌជាច្រើន ដើម្បីលៃលកឲ្យជនជាប់ចោទនូវឱកាសដើម្បីឆ្លើយទៅនឹងសំណួរ។ ដូច្នេះ សហព្រះរាជអាជ្ញា៖ ក) បានយល់ព្រមផ្តល់ដល់ជនជាប់ចោទ ក្នុងរយៈពេលចំនួន២៤ម៉ោង នូវបញ្ជីមួយស្តីពីប្រធានបទនានាដែលខ្លួននឹងត្រូវបានសួរដេញដោល ក៏ដូចជាបញ្ជីមួយស្តីពីឯកសារនានាដែលនឹងត្រូវប្រើប្រាស់នៅក្នុងការសួរដេញដោលគាត់ផងដែរ, និង ខ) បានបញ្ជាក់ថាខ្លួននឹងមិនជំទាស់ទៅនឹងការផ្តល់ពេលវេលាបន្ថែមឲ្យដល់ជនជាប់ចោទ សម្រាប់ធ្វើការត្រៀមរៀបចំនោះទេ[9]។ សហព្រះរាជអាជ្ញាក៏បានជូនសេចក្តីសន្និដ្ឋានផងដែរថា ជនជាប់ចោទបានធ្វើការលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបនេះ ជាឯកតោភាគី និងដោយគ្មានការកែប្រែ ដោយមិនផ្តល់ភស្តុតាងនៅក្នុងពេលសវនាការ ហើយថា នៅក្នុងកាលៈទេសៈទាំងនេះ បើគាត់បញ្ជាក់ពីការបដិសេធមិនព្រមឆ្លើយ សំណួរនៅក្នុងដំណាក់កាលនេះនៃសវនាការទេ អង្គជំនុំជម្រះសាលាដំបូងគប្បីទាញសេចក្តីសន្និដ្ឋានអវិជ្ជមានពីការនៅស្ងៀមមិននិយាយរបស់គាត់[10]។

---

[6] **E288/4** សេចក្តីជូនដំណឹងស្តីពីការដកខ្លួន, ត្រង់កថាខណ្ឌទី ១១-៤០។

[7] អ៊ីម៉ែលរបស់លោក William Smith និង Matteo Crippa, ៨ កក្កដា ២០១៣។

[8] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី២៨។

[9] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី ៣២-៣៣។

[10] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី ៣៣-៣៥។

៤- នៅពេលដែល ខៀវ សំផន ត្រូវបានសួរដោយអង្គជំនុំជម្រះសាលាដំបូង ថាតើគាត់យល់ព្រមឲ្យសួរដេញដោលពីសំណាក់ចៅក្រម និងពីភាគីដទៃទៀត ទាក់ទងនឹងការយល់ព្រមបន្ថែមដាក់ដោយសហព្រះរាជអាជ្ញា ដែរ ឬទេ ជនជាប់ចោទបានឆ្លើយថា គាត់មិនយល់ព្រមទេ[11]។ នៅក្នុងការស្វែងរកនូវការពន្យល់មួយលើសេចក្តីសម្រេចនេះ មេធាវីការពារក្តី និងជនជាប់ចោទបានផ្តោតតែមួយគត់ទៅលើការមិនយល់ព្រមរបស់គាត់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើបញ្ហានានាដែលមិនមានការទាក់ទងទៅនឹងការផ្តល់ សក្ខីកម្មរបស់ជនចាប់ចោទ[12]។

៥- តាមរយៈនេះ សហព្រះរាជអាជ្ញាធ្វើការឆ្លើយតបជាលាយលក្ខណ៍អក្សរទៅនឹងសេចក្តីជូនដំណឹង ស្តីពីការដកខ្លួន និងសារណាផ្ទាល់មាត់របស់មេធាវីការពារក្តី ដូចដែលបានបញ្ជាក់នៅក្នុងអំឡុងពេលនៃការធ្វើសេចក្តីសន្និដ្ឋានរបស់ខ្លួននៅក្នុងសវនាការដូច្នោះដែរ[13]។ ក្នុងពាក្យពេចន៍មុឺងម៉ាត់បំផុតរបស់ខ្លួន សហព្រះរាជអាជ្ញាទទូចម្តងទៀតថា ការអះអាងរបស់ជនជាប់ចោទ ដែលថាសិទ្ធិរបស់គាត់អាចត្រូវបានរំលោភ ប្រសិនបើគាត់ត្រូវឆ្លើយទៅនឹងសំណួរដោយគ្មានលក្ខខណ្ឌទាំងអស់របស់គាត់មិនទាន់ត្រូវបានបំពេញនោះ <u>គឺមិនមានមូលដ្ឋានច្បាប់ និងអង្គហេតុទេ</u>។ ពុំមានសិទ្ធិណាមួយនៅក្នុងច្បាប់ ឬនីតិវិធីណាមួយនៅក្នុងការអនុវត្តសម្រាប់ឲ្យគេផ្តល់ជាបញ្ជីសំណួរ ឬបញ្ជីឯកសារឲ្យដល់ជនជាប់ចោទ នៅមុនពេលដែលជនជាប់ចោទត្រូវបានសួរដេញដោលដោយព្រះរាជអាជ្ញានោះទេ។ យ៉ាងណាក៏ដោយ សហព្រះរាជអាជ្ញាបានត្រៀមរៀបចំផ្តល់នូវលក្ខខណ្ឌទាំងនោះ (ដូចដែលបានសង្ខេបនៅខាងលើស្រាប់) ដើម្បីកុំឲ្យមានការលើកឡើងថា អង្គជំនុំជម្រះសម្រេចលែងផ្តល់វេទិការសមហេតុសមផលដើម្បីផ្តល់ឱកាសឲ្យដល់ជនជាប់ចោទក្នុងការផ្តល់សក្ខីកម្ម មុននឹងធ្វើសេចក្តីសន្និដ្ឋានអវិជ្ជមានប្រឆាំងនឹងរូបគាត់។

៦- សហព្រះរាជអាជ្ញាជូនសេចក្តីសន្និដ្ឋានបន្ថែមទៀតថា បណ្តឹងបន្ទាប់បន្សំផ្សេងៗទៀតដែលបានលើកឡើងដោយមេធាវីការពារក្តីនោះ គឺត្រូវបានប្តឹង និងត្រូវបានវិនិច្ឆ័យរួចរាល់អស់ហើយ ហើយការរៀបរាប់របស់មេធាវីការពារក្តីលើបញ្ហាទាំងនោះ គឺធ្វើឲ្យមានការយល់ខុស និង/ឬ ដោយមានការក្លែងហើយសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះយុត្តិធម៌នោះ គឺមិនត្រូវបានរំលោភដោយប្រការណាមួយឡើយ។

---

[11] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី ៤១-៤២។

[12] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី៤១, ៤៣-៤៧។

[13] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី២៨។

៧- សហព្រះរាជអាជ្ញាស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងធ្វើការបញ្ជាក់សាជាថ្មីថា បើ ខៀវ សំផន ខកខាន មិនបានផ្តល់សក្ខីកម្ម នោះខ្លួននឹងធ្វើសេចក្តីសន្និដ្ឋានអវិជ្ជមាន ចេញពីបទប្បញ្ញត្តិ ភ័ស្តុតាងដែលបាន ជ្រើសរើសរបស់គាត់។ ជាការបន្ថែមទៀត សហព្រះរាជអាជ្ញាស្នើឲ្យមានឱកាសដើម្បីបានថ្លែងនៅ ក្នុងអង្គជំនុំជម្រះ នៅចំពោះមុខវត្តមានរបស់ ខៀវ សំផន អំពីប្រធានបទ និងអង្គហេតុនានា ដែល អង្គជំនុំជម្រះនឹងត្រូវសួរសំណួរទៅកាន់រូបគាត់ ហើយសហព្រះរាជអាជ្ញានឹងស្នើដល់អង្គជំនុំជម្រះ ឲ្យធ្វើសេចក្តីសន្និដ្ឋានអវិជ្ជមាន ដែលជាផ្នែកនៃសេចក្តីសន្និដ្ឋានបញ្ចប់ការសួរដេញដោលរបស់គាត់។ សហព្រះរាជអាជ្ញាដាក់ជូននូវសេចក្តីសន្និដ្ឋានថា សេចក្តីថ្លែងនេះត្រូវតែបានធ្វើឡើងនៅមុនពេល បញ្ចប់កិច្ចដំណើរការនីតិវិធីសួរដេញដោលលើភ័ស្តុតាង។

## II. អំណះអំណាង

***ក. លក្ខខណ្ឌដែលមេធាវីការពារក្តីបានស្នើសុំពាក់ព័ន្ធនឹងសក្ខីកម្មរបស់ ខៀវ សំផន គឺមិនមានមូលដ្ឋានលើ សិទ្ធិទទួលបានការជំនុំជម្រះក្តីយុត្តិធម៌នោះទេ***

៨- មេធាវីកាពារក្តីបានធ្វើជាបញ្ជីនូវលក្ខខណ្ឌចំនួនប្រាំដែលបានស្នើសុំ ពាក់ព័ន្ធនឹងការសួរដេញដោល ខៀវ សំផន ការច្រានចោលលក្ខខណ្ឌនោះ គឺជាមូលហេតុដើមដំបូងដែលបានអះអាងក្នុងការសម្រេច ចិត្តមិនផ្តល់សក្ខីកម្ម។ លក្ខខណ្ឌទាំងអស់នោះគឺ៖

ក. បញ្ជីមួយពីភាគីនានា និងពីអង្គជំនុំជម្រះសាលាដំបូង ស្តីពីសំណួរនានា(តាមប្រធានបទ) ដែល ត្រូវសួរទៅកាន់ជនជាប់ចោទ។

ខ. បញ្ជីមួយពីភាគីនានា និងពីអង្គជំនុំជម្រះសាលាដំបូង ស្តីពីឯកសារនានាដែលពួកគេចង់ប្រើ ប្រាស់ក្នុងអំឡុងពេលសួរដេញដោល។

គ. រយៈពេលចំនួនបីសប្តាហ៍សម្រាប់ធ្វើការត្រៀមរៀបចំ ដោយពុំមានសវនាការចាប់ពីពេលដែល មានបញ្ញត្តិស្តីពីបញ្ជីសំណួរ និងឯកសារ។

ឃ. បញ្ញត្តិស្តីពីការដែលក្រុមមេធាវីការពារក្តីអាចចូលទៅមើលអង្គភាពមន្ទីរឃុំឃាំង អ.វ.ត.ក នៅថ្ងៃចុងសប្តាហ៍, និង

ង. ខៀវ សំផន ត្រូវបានរៀបចំកាលវិភាគឲ្យធ្វើការផ្តល់សក្ខីកម្មចំនួនកន្លះថ្ងៃតែប៉ុណ្ណោះ[14]។

៩- ដោយពុំមានប្រភពច្បាប់ មេធាវីការពារក្តីបានអះអាងថា សំណើទាំងនេះ គឺជាការអនុវត្តទូទៅ នៅគ្រប់តុលាការព្រហ្មទណ្ឌអន្តរជាតិទាំងអស់ ហើយជាពិសេសគឺមានលក្ខណៈសមស្របនៅ អ.វ.ត.ក[15]។ តាមអង្គហេតុពិត ដូចដែលសហព្រះរាជអាជ្ញាបានថ្លែងនៅក្នុងអង្គជំនុំជម្រះ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ ដូច្នេះដែរថា មិនមានលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌទាំងនេះ ជាលក្ខខណ្ឌតម្រូវនៅក្រោមច្បាប់អន្តរជាតិនោះឡើយ។ មេធាវីការពារក្តីបានយោងទៅលើរឿងក្តីចំនួនពីរ នៅក្នុងការគាំទ្រដល់ការអះអាងដែលថាលក្ខខណ្ឌនានាដែលបានស្នើសុំនេះ គឺមិនមានការងាកចេញពីការអនុវត្តជាអន្តរជាតិនោះទេ (រឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Mpambara* និងរឿងក្តីរវាង *រដ្ឋអាជ្ញា ទល់នឹង Kalimanzira*)[16] ប៉ុន្តែវាទំនងជាមិនមានជំនឿគ្រប់គ្រាន់ស្តីពីភាពពាក់ព័ន្ធទៅនឹងសេចក្តីសម្រេចនានាដែលបានចោទប្រកាន់ ដើម្បីឲ្យមានជាការលើកឡើងជាក់លាក់អំពីសេចក្តីសម្រេច និងអំពីកថាខណ្ឌផ្សេងៗ ដែលគាំទ្រដល់ការអះអាងទាំងស្រុងនេះ។ តាមអង្គហេតុពិត សូម្បីតែយោងទៅតាមការរៀបរាប់ផ្ទាល់របស់មេធាវីការពារក្តីក៏ដោយក៏ រឿងក្តីទាំងនេះមានទាក់ទងតែទៅលើការផ្តល់ពេលវេលាត្រៀមរៀបចំ នៅមុនពេលផ្តល់សក្ខីកម្មប៉ុណ្ណោះ គឺមិនមែនទាក់ទងទៅនឹងលក្ខខណ្ឌណាមួយក្នុងចំណោមលក្ខខណ្ឌផ្សេងៗទាំងនោះដែលជនជាប់ចោទបានស្នើសុំនោះឡើយ។

១០- យ៉ាងណាក៏ដោយ ដូចដែលបានថ្លែងនៅខាងលើស្រាប់ សហព្រះរាជអាជ្ញាបានត្រៀមរៀបចំផ្តល់ ជាបញ្ជីមួយស្តីពីប្រធានបទនានា ដែលខ្លួនមានបំណងសួរដេញដោលដល់ជនជាប់ចោទ[17] ក៏ដូចជាត្រៀមរៀបចំជាបញ្ជីមួយស្តីពីឯកសារនានា ដែលខ្លួនមានបំណងនឹងប្រើប្រាស់នៅក្នុង អំឡុងពេលនៃការសួរដេញដោល នៅលើបញ្ញត្តិដែលថាវាមិនអាចធ្វើជាបញ្ជីផ្តាច់ព្រ័តជាមុនបាន ចំពោះឯកសារនីមួយៗ ឬអនុប្រធានបទនីមួយៗ ដែលអាចនឹងក្លាយទៅជាមានការពាក់ព័ន្ធនៅក្នុងអំឡុងពេលនៃការសួរ

[14] **E288/4** សេចក្តីជូនដំណឹងស្តីពីការដកខ្លួន, ត្រង់កថាខណ្ឌទី៧។

[15] **E288/4** សេចក្តីជូនដំណឹងស្តីពីការដកខ្លួន, ត្រង់កថាខណ្ឌទី៧។

[16] **E288/4** សេចក្តីជូនដំណឹងស្តីពីការដកខ្លួន, ត្រង់កថាខណ្ឌទី២៦។

[17] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី៣២។ មេធាវីការពារក្តីធ្លាប់បានធ្វើការកត់សម្គាល់ពីមុនមកថាគេគ្រាន់តែស្វែងរកនូវបញ្ជីទូទៅមួយស្តីពីប្រធានបទ។ *សូមអាន* **E1/197.1** ប្រតិចារឹក, ២៧ ឧសភា ២០១៣, ត្រង់ទំព័រទី ៣-៤ ("អ្វីដែលស្នើសុំនោះ គឺថាមិនមែនគ្រប់សំនួរទាំងអស់នោះទេ គឺគ្រាន់តែលោក ខៀវ សំផន គាត់ចង់បានប្រធានបទ ចង់ដឹងថាគេនិយាយ -- ចង់សួរគាត់ពីប្រធានបទអី? ហើយមានឯកសារអីខ្លះ ... ដូច្នេះអ្វីដែលគាត់ស្នើសុំហ្នឹង គឺសូមឲ្យមានជាប្រធានបទជាក់លាក់ ហើយនិងកាលវិភាគ")។

ដេញដោល[18]។ សហព្រះរាជអាជ្ញារំលឹកពីការបញ្ជាក់របស់លោកប្រធាន ដល់ជនជាប់ចោទដែលថា គេមិនអាចផ្តល់ជាមុននូវបញ្ជីសំនួរដែលត្រូវសួរដេញដោលបាននោះទេ ដោយលោកប្រធានបានថ្លែងថា៖ "ការសួរដេញដោលវាមិនអាចគ្រោងថា មួយសំនួរ នេះចប់ ឬក៏១០សំនួរទេ គឺអាចប្រើប្រាស់នូវសំណួរច្រើន។ ដូច្នេះអាចមានបញ្ហាប្រទាក់ក្រឡាគ្នានូវសំណួរដេញដោល។ ពាក្យថា "សួរ តាំងសំណួរដេញដោល" នេះវាមិនមែនជាងាយក្នុងការយើងដាក់សំណួរធម្មតាដូចនៅសាលារៀនទេ"[19]។

១១- សហព្រះរាជអាជ្ញាក៏មិនធ្វើការជំទាស់ទៅនឹងការបន្ថែមពេលវេលាណាមួយ ដែលអង្គជំនុំជម្រះសាលាដំបូងយល់ឃើញថាជាការចាំបាច់ ដើម្បីអនុញ្ញាតឲ្យ ខៀវ សំផន និងមេធាវីការពារក្តីរបស់ខ្លួនធ្វើការត្រៀមរៀបចំសម្រាប់ការផ្តល់សក្ខីកម្មរបស់ជនជាប់ចោទនោះទេ ដោយកត់សម្គាល់ឃើញថា ជនជាប់ចោទមានសិទ្ធិចូលទៅពិនិត្យមើលសំណុំរឿងអស់ពេលជាងប្រាំឆ្នាំមកហើយនោះ ដែលរូបគាត់ត្រូវបានធ្វើជាតំណាងដោយមេធាវីជាតិ និងអន្តរជាតិនៅក្នុងទូទាំងអម្តុងពេលនៃកិច្ចស៊ើបសួរ និងការជំនុំជម្រះក្តី ហើយថាគាត់និងមេធាវីការពារក្តីរបស់គាត់បានស្តាប់ និងធ្វើតេស្តពិសោធន៍លើភ័ស្តុតាងដែលត្រូវបានផ្តល់ជូននៅក្នុងតុលាការអស់រយៈពេលជាងមួយឆ្នាំកន្លះមកហើយនោះ។ សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ចំពោះរឿងនេះថា ខៀវ សំផន បានបញ្ជាក់ជូនអង្គជំនុំជម្រះ និងភាគីនានាថា គាត់មានបំណងនឹងផ្តល់ជូននូវភ័ស្តុតាង តាំងពីដើមខែមីនា ឆ្នាំ២០១១ មកម្ល៉េះ[20]។

១២- ចំពោះពាក្យបណ្តឹងរបស់មេធាវីការពារក្តី ទាក់ទងនឹងការរឹតត្បឹតសិទ្ធិក្នុងការចូលទៅកាន់មន្ទីរឃុំឃាំងនោះ សហព្រះរាជអាជ្ញាបានកត់សម្គាល់ថា បន្ទាប់ពីការលើកឡើងអំពីរឿងនេះជូនអង្គជំនុំជម្រះសាលាដំបូងកាលពីក្នុងខែសីហា ឆ្នាំ២០១២មក[21]។ មេធាវីការពារក្តីហាក់ដូចជាមិនបានខំប្រឹងតស៊ូអំពីបញ្ហានេះទៅទៀតនោះទេ នៅមុនពេលលើកឡើងអំពីបញ្ហានេះ នៅពេល១០ខែក្រោយមកទៀតនៅក្នុងពេលប្រជុំស្តីពីការរៀបចំសវនាការនៅក្នុងខែមិថុនា ឆ្នាំ២០១៣[22]។ ការប្រព្រឹត្តិដោយយឺតយ៉ាវនេះ បង្ហាញពីការគេចដោយគ្មានភាពពិតប្រាកដចេញពីការពឹងផ្អែករបស់មេធាវីការពារក្តី ទៅលើបញ្ហាស្តីពីសិទ្ធិក្នុងការចូលទៅពិនិត្យមើលសំណុំរឿង នៅក្នុងបរិបទស្តីពីការបដិសេធមិនផ្តល់សក្ខីកម្មរបស់

---

[18] សេចក្តីព្រាងប្រតិចារឹក, ៩ កក្កដា ២០១៣, ត្រង់ទំព័រទី៣២។

[19] **E1/197.1** ប្រតិចារឹក, ២៧ ឧសភា ២០១៣, ត្រង់ទំព័រទី៣។

[20] *សូមអាន* **E9/17** អង្គហេតុដែលមិនជំទាស់, ត្រង់កថាខណ្ឌទី៥។

[21] **E288/4** សេចក្តីជូនដំណឹងស្តីពីការដកខ្លួន, ត្រង់កថាខណ្ឌទី១៩ ។

[22] ឯកសារលេខ **E1/207.1** ប្រតិចារឹក ថ្ងៃទី១៣ មិថុនា ២០១៣, ត្រង់ទំព័រ១៩។

ខៀវ សំផន។ នៅដំណាក់កាលណាក៏ដោយ នៅចន្លោះរវាងខែសីហា ឆ្នាំ២០១២ និងខែមិថុនា ឆ្នាំ២០១៣ គឺពុំដែលមានទាល់តែសោះថា មេធាវីការពារក្តីបានចោទប្រកាន់ថា លទ្ធភាពរបស់ខ្លួននៅក្នុងការត្រៀមរៀបចំសម្រាប់ដំណើរការនីតិវិធី ឬក្នុងការទទួលនូវការណែនាំពីកូនក្តីរបស់ខ្លួនត្រូវបានរងនូវផលប៉ះពាល់បញ្ច្រាស់មកវិញដោយសារតែការសម្រួលរៀបចំរបស់មន្ទីរឃុំឃាំងនោះឡើយ។

១៣- ជាទីបញ្ចប់ ដូចដែរសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ផងដែរនៅក្នុងតុលាការ អង្គជំនុំជម្រះសាលាដំបូងបានយល់ព្រមអនុញ្ញាតតាមសំណើរបស់ ខៀវ សំផន ហើយថា ឲ្យធ្វើសក្ខីកម្មនៅក្នុងរយៈពេលកន្លះថ្ងៃនៃសវនាការតែប៉ុណ្ណោះ[23]។

១៤- ការជួយសម្រួលផ្សេងៗដែលបានស្នើសុំនៅក្នុងពេលសវនាការកាលពីថ្ងៃទី៩ ខែកក្កដា ហើយដែលត្រូវបានលើកសាជាថ្មីឡើងវិញខាងលើនេះ លើកឡើងអំពីខ្លឹមសារនៃលក្ខខណ្ឌទាំងអស់ ដែលជនជាប់ចោទស្វែងរកដើម្បីដាក់តម្រូវទៅលើការសួរដេញដោលរបស់ខ្លួន។

១៥- ទោះជាយ៉ាងនេះក៏ដោយ នៅពេលដែល ខៀវ សំផន ត្រូវបានសួរដោយប្រធានអង្គជំនុំជម្រះអំពីថាតើគាត់នឹងយល់ព្រមផ្តល់សក្ខីកម្មដែរឬទេបើសិនជាការជួយសម្រួលទាំងនេះត្រូវបានធ្វើឡើង?[24]។ ជនជាប់ចោទបានថ្លែងថា "ការអនុវត្តនេះមិនបានកម្រិតចំពោះការពិតដែលថា តុលាការមិនបានពិចារណាតាមផ្លូវតុលាការនូវសំណើទាំងឡាយរបស់ខ្ញុំដូចដែលបានបញ្ជាក់នោះទេ។ នៅពីក្រោយសេចក្តីសម្រេចនេះ មានការជាប់ជំពាក់ទាក់ទងផ្សេងៗទៀតទៅនឹងច្បាប់..."[25]។ ក៏ប៉ុន្តែគាត់បានលើកសំអាងថា គឺមានមូលហេតុតែមួយប៉ុណ្ណោះ ដែលជាការដាក់តម្រូវអំពីចំនួនទំព័រកំណត់សម្រាប់សារណាបិទការពិភាក្សាដេញដោលដែលអះអាងថា នេះគឺជាផ្នែកនៃ "ចេតនារបស់តុលាការដែលមានបំណងចង់រារាំងមេធាវីការពារក្តីរបស់ខ្ញុំមិនឲ្យធ្វើជាតំណាងត្រឹមត្រូវឲ្យខ្ញុំនៅក្នុងសាលសវនាការ"[26]។ ប្រធានបទដដែលនេះត្រូវបានលើកឡើងដោយលោកចៅក្រម Lavergne ដែលលោកបានកត់សម្គាល់ថា សម្បទានដែលបានធ្វើឡើងដោយសហព្រះរាជអាជ្ញានឹងអនុញ្ញាតឲ្យក្រុមមេធាវីការពារក្តីរបស់ ខៀវ

[23] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ២៨។ អ៊ីម៉េល ពីមន្ត្រីជាន់ខ្ពស់ទទួលបន្ទុកផ្នែកច្បាប់, ចុះថ្ងៃទី៨ កក្កដា ២០១៣។

[24] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤១។

[25] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤១។

[26] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤១។

សំផន ត្រៀមលក្ខណៈដើម្បីសួរសំណួរដេញដោលអំពីកូនក្តីរបស់ខ្លួន”[27]។ ជាការឆ្លើយតប មេធាវីការពារក្តីដែលបានយោងទៅលើការពោលអះអាងអំពីការរំលោភសិទ្ធិមួយចំនួនធំ ដែលមិនមានជាប់ទាក់ទងគ្នាទាំងស្រុងទៅនឹងការសួរសំនួរដេញដោលអំពីជនជាប់ចោទនោះឡើយ[28]។ មេធាវី Verken នៅពេលត្រូវបានលោកចៅក្រម Lavergne ស្នើសុំឱ្យពន្យល់អំពី “តើបញ្ហាដោយឡែកនេះមិនមានទាក់ទងទាល់តែសោះបែបដូចម្តេចខ្លះ ទៅនឹងចេតនារបស់ ខៀវ សំផន ក្នុងការឆ្លើយទៅសំណួរដេញដោល?”[29] ដោយយោងទៅលើបទដ្ឋានដែលបានអនុម័តដោយអង្គជំនុំជម្រះសម្រាប់ការទទួលយកភ័ស្តុតាងជាឯកសារ[30](សេចក្តីសម្រេចមួយដែលបានធ្វើឡើងជាងមួយឆ្នាំមកហើយ[31]) ហើយបានលើកឡើងអះអាងថាមេធាវីការពារក្តីកំពុងតែត្រូវបានគេដាក់ “អន្ទាក់” និង “ប្រើល្បិច”[32]។

១៦- គឺជាការបង្ហាញយ៉ាងច្បាស់ណាស់ថា ជនជាប់ចោទ តាមការណែនាំរបស់មេធាវីការពារក្តីរបស់ខ្លួន បានធ្វើការសម្រេចចិត្តដើម្បីដកខ្លួនថយពីការផ្តល់សក្ខីកម្មវិញ ដោយសារមូលហេតុមួយចំនួនដែលមិនជាប់ទាក់ទងទៅនឹងវិធីសាស្រ្តនៃការធ្វើសក្ខីកម្មរបស់ខ្លួន ឬក៏ទៅនឹងសេចក្តីព្រួយបារម្ភផ្សេងទៀតដែលបានសន្មតនោះដែរ។ ផ្ទុយទៅវិញ មេធាវីការពារក្តីបានខំព្យាយាមដើម្បីចងការសម្រេចនេះទៅនឹងសេចក្តីសម្រេចជាច្រើនទៀតរបស់អង្គជំនុំជម្រះសាលាដំបូង ដែលពួកគេមិនយល់ព្រម ហើយដែលពួកគេបង្ហាញជូននូវការបកស្រាយដែលធ្វើឱ្យមានការយល់ច្រឡំទាំងស្រុងទៅលើសេចក្តីសម្រេចទាំងនោះ។

១៧- ដើម្បីជៀសវាងនូវការមន្ទិលសង្ស័យ សហព្រះរាជអាជ្ញា បន្តត្រៀមលក្ខណៈក្នុងការផ្តល់ការអនុញ្ញាតឱ្យជនជាប់ចោទ និងមេធាវីការពារក្តី នូវការជួយសម្រួលមួយចំនួន ដែលមិនមានការតម្រូវតាមច្បាប់ដូចដែលបានធ្វើការកត់សម្គាល់ខាងលើ ហើយហេតុនេះនឹងបើកឱ្យពួកគេ មានយុទ្ធសាស្រ្តដ៏មានផលប្រយោជន៍បន្ថែមទៀត ដើម្បីត្រៀមរៀបចំការសម្រាប់ការផ្តល់សក្ខីកម្មរបស់ ខៀវ សំផន។

---

[27] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤២។

[28] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤៣-៤៧។

[29] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤២-៤៣។

[30] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤៣។

[31] **ឯកសារE185** សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះនៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំនាក់កាលដំបូងនៃសំណុំរឿងលេខ០០២/០១, ត្រង់កថាខណ្ឌទី២០-៣៦ ចុះថ្ងៃទី៩ មេសា ២០១២។

[32] សេចក្តីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៤៥។

### *ខ. ការចោទប្រកាន់របស់មេធាវីការពារក្ដីអំពីការរំលោភផ្សេងទៀតទៅលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយត្រឹមត្រូវគឺគ្មានមូលដ្ឋាន*

១៨- ដូចបានលើកឡើងខាងលើ តាមរយៈការដកមកវិញនូវសេចក្ដីជូនដំណឹង និងការធ្វើសារណាដោយផ្ទាល់មាត់របស់ពួកគេ កាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ មេធាវីការពារក្ដីបានចោទប្រកាន់អំពីការរំលោភបំពានមួយចំនួនទៅលើសិទ្ធិក្នុងការទទួលបាននូវការជំនុំជម្រះក្ដីដោយត្រឹមត្រូវរបស់ ខៀវ សំផន ដែល ក) គ្មានមូលដ្ឋានទាំងស្រុង និង ខ) ពុំមានការជាប់ទាក់ទងទៅនឹងសក្ខីកម្មរបស់ជនជាប់ចោទឡើយ។ រាល់បញ្ហាទាំងអស់នេះកាលពីមុនធ្លាប់ត្រូវបានយកមកជជែកតតាំងគ្នានៅចំពោះមុខអង្គជំនុំជម្រះរួចមកហើយ ដែលនៅក្នុងពេលនោះ មេធាវីការពារក្ដីត្រូវបានផ្ដល់ឱកាសឲ្យបង្ហាញពីទស្សនៈរបស់ខ្លួន នឹងអំណះអំណាងយ៉ាងល្អប្រសើរបំផុត។ ដូចដែលលោកស្រីចៅក្រម Cartwright បានថ្លែងនៅក្នុងតុលាការថា "អង្គជំនុំជម្រះបានផ្ដល់ឲ្យ ខៀវ សំផន និងក្រុមមេធាវីការពាររបស់ខ្លួនយ៉ាងត្រឹមត្រូវនូវឱកាសដូចគ្នា ដើម្បីឆ្លើយតបទៅនឹងរាល់បញ្ហាទាំងអស់នៅក្នុងពេលសវនាការ"[33]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងដែរអំពីបញ្ហានីមួយៗក្នុងចំណោមបញ្ហាទាំងនេះដូចដែលពួកគេបានលើកឡើង ហើយហេតុដូចនេះ នឹងគ្រាន់តែលើកឡើងនៅទីនេះ ដោយសង្ខេបខ្លីៗដើម្បីគូសបញ្ជាក់អំពីការខ្វះមូលដ្ឋាននៃការចោទប្រកាន់របស់មេធាវីការពារក្ដីតែប៉ុណ្ណោះ។

១៩- ទីមួយ មេធាវីបានលើកយោងទៅលើវិសាលភាពនៃការជំនុំជម្រះក្ដី និងអំពីការសួរដេញដោលដែលអាចត្រូវបានផ្ដោតទៅលើ ខៀវ សំផន ពាក់ព័ន្ធនឹងរចនាសម្ព័ន្ធរដ្ឋបាល និងសហកម្មឧក្រិដ្ឋកម្មរួមដែលបានចោទប្រកាន់[34]។ ទោះជាមានសេចក្ដីណែនាំជាលាយលក្ខណ៍និងដោយផ្ទាល់មាត់ជាច្រើនរបស់អង្គជំនុំជម្រះលើបញ្ហានេះយ៉ាងណាក្ដីក៏ (សេចក្ដីណែនាំផ្ទាល់មាត់ជាទូទៅជាការឆ្លើយតបទៅនឹងការជំទាស់របស់មេធាវីការពារក្ដីដែលតែងតែខំស្វែងរកធ្វើយ៉ាងណា ដើម្បីកម្រិតអំពីភ័ស្តុតាងដែលសហព្រះរាជអាជ្ញាអាចបង្ហាញភស្តុតាងបានដើម្បីបំពេញតាមតួនាទី ក្នុងការបង្ហាញភ័ស្តុតាងរបស់ខ្លួន)វិសាលភាពនៃសវនាការនេះហាក់ដូចបង្វែរទិសក្រុមមេធាវីការពារក្ដី។ ដូចដែលអង្គជំនុំជម្រះនេះបានថ្លែង ក្នុងពេលថ្មីៗនេះថា "ចាប់តាំងពីការចាប់ផ្ដើមដំបូងមក អង្គជំនុំជម្រះបានសម្រេច

---

[33] សេចក្ដីព្រាងប្រតិចារឹក ថ្ងៃទី៩ កក្កដា ២០១៣, ត្រង់ទំព័រ៥១។

[34] ឯកសារលេខ **E288/4** ការដកសេចក្ដីជូនដំណឹងមកវិញ, ត្រង់កថាខណ្ឌទី១៤។

ថា គ្រប់ភាគីទាំងអស់អាចដឹកនាំភស្តុតាងនានាដែលទាក់ទងនឹងតួនាទី និងការទទួលខុសត្រូវរបស់ជនជាប់ចោទទាំងអស់ដែលពាក់ព័ន្ធនឹងគោលនយោបាយទាំងអស់ នៅក្នុងសម័យកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ"[35]។ អង្គជំនុំជម្រះសាលាដំបូងក៏បានដាក់បញ្ចូលផងដែរ ចាប់តាំងពីការចាប់ផ្តើតពីដំបូងនូវរាល់កថាខណ្ឌទាំងអស់នៃដីកាដំណោះស្រាយដែលទាក់ទងនឹងរចនាសម្ព័ន្ធរដ្ឋបាល នៅក្នុងការជំនុំជម្រះក្តីលើសំណុំរឿងលេខ០០២/០១[36]។ មេធាវីការពារក្តីមិនអាចលើកឡើងអះអាងដែលមិនគួរឲ្យជឿ ថា ភាពមិនប្រាកដប្រជាដែលទាក់ទងនឹងវិសាលភាពនៃការសួរដេញដោលថា ជាការកើតទុក្ខមិនសុខចិត្តដោយត្រឹមត្រូវតាមច្បាប់នោះឡើយ។

២០- ទីពីរ នៅពេលនេះមេធាវីការពារក្តីប្តឹងថា សហមេធាវីការពារក្តីចំនួនពីរនាក់ក្នុងចំណោមបួននាក់របស់ ខៀវ សំផន មិនបានចូលរួមនៅក្នុងករណីនេះរឿងក្តីនេះទេ រហូតដល់ខែវិច្ឆិកា ឆ្នាំ២០១១ ហើយចំណែកឯមេធាវីទីបីវិញ បានចូលរួមនៅក្នុងខែមករា ឆ្នាំ២០១២ ដែលអាស្រ័យហេតុនេះហើយបានជាពួកគេមិនមានឱកាសគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំ[37]។ ប៉ុន្តែ ដូចដែរមេធាវីការពារក្តី គង់ សំអុន, Verken, និង Guissé ខ្លួនឯង បានទទួលស្គាល់មិនមានដំណាក់កាលណាមួយ ដែលពួកគេស្វែងសុំឲ្យផ្អាកកិច្ចដំណើការសួរដេញដោលលើភស្តុតាងនោះឡើយ ហើយពួកខ្លួនក៏មិនដែរត្អូញត្អែរអំពីការកំណត់ពេល ឬអំពីល្បឿននៃដំណើរការនីតិវិធីដែលរឹតត្បិតដល់លទ្ធភាពរបស់ពួកខ្លួន នៅក្នុងការបំពេញមុខងាររបស់ខ្លួន។ អាស្រ័យហេតុដូចនេះ គឺជាការផលិតនូវការលើកឡើង ដោយយឺតយ៉ាវដែលធ្វើឡើងរយៈពេលមួយឆ្នាំកន្លះ ក្រោយពីការតែងតាំងរបស់មេធាវី ហើយដែលធ្វើការវិចខ្ចប់ដោយមានការមិនប៉ិនប្រសប់ជាមួយនឹងពាក្យបណ្តឹងដែលពុំមានមូលដ្ឋានដទៃទៀត ដើម្បីបង្កើតដោយប្រតិសកម្មជារូបភាពមួយដែលសន្មតថាជាការលំបាកដែលមិនអាចពុះពារបាន ដែលមេធាវីការពារក្តីបានប្រឈមមុខ។ មេធាវីការពារក្តីម្នាក់ៗ ក្នុងចំណោមមេធាវីទាំងនេះ ព្រមជាមួយនឹងក្រុមអ្នកផ្តល់យោបល់ប្រឹក្សាបាន និងកំពុងធ្វើជាតំណាងឲ្យកូនក្តីរបស់ខ្លួនអស់រយៈពេលជាងមួយឆ្នាំកន្លះមកហើយ។ ចំណែកឯ សហមេធាវីទីបួន Jacques Verges វិញបាន និងកំពុងតែធ្វើជាតំណាងឲ្យគាត់ចាប់តាំងពីខែធ្នូ ឆ្នាំ២០០៧ មកម្ល៉េះ[38]។ នៅក្នុងអម្លុងពេលនេះ គាត់បានដាក់ញត្តិស្នើសុំ បណ្តឹងសាទុក្ខ សំណើ

[35] ឯកសារលេខ **E284** សេចក្តីសម្រេចចុះថ្ងៃទី២៦មេសា ឆ្នាំ២០១៣ ស្តីពីការបំបែកកិច្ចដំណើរការនីតិវិធីនៃសំណុំរឿងលេខ ០០២ បន្ទាប់ពីមានសេចក្តីសម្រេច របស់អង្គជំនុំជម្រះតុលាការកំពូល ចុះថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០១៣ កថាខណ្ឌទី១១៧។

[36] *សូមអាន* ឯកសារលេខ **E124/7.3** ឧបសម្ព័ន្ធស្តីពីការបំបែកកិច្ចដំណើរការនីតិវិធី, ត្រង់ទំព័រ១។

[37] ឯកសារលេខ **E288/4** សេចក្តីជូនដំណឹងពីការដកខ្លួន, ត្រង់កថាខណ្ឌទី១៥។

[38] **D45** សេចក្តីសម្រេចស្តីពីការទទួលស្គាល់មេធាវី ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧។

ចំនួនរាប់សិប ហើយបានជំទាស់ ជាលាយលក្ខណ៍អក្សរ ទៅនឹងញត្តិភាគច្រើនដែលបានដាក់ដោយសហព្រះរាជអាជ្ញា។ មេធាវីការពារក្តីបានទទួលភារៈក្នុងការសួរដេញដោលយ៉ាងល្អិតល្អន់ទៅលើសាក្សី និងអ្នកជំនាញនានារបស់ភាគីបដិបក្ស ដែលបានផ្តល់ភ័ស្តុតាងដាក់ពិរុទ្ធលើកូនក្តីរបស់ខ្លួន។ ហើយពួកខ្លួនបានឆ្លៀតឱកាសក្នុងការតវ៉ាជំទាស់ចំពោះការទទួលយកនូវរាល់ភ័ស្តុតាងជាឯកសារទាំងអស់ដែលបានស្នើឡើងដោយសហព្រះរាជអាជ្ញា។ អាស្រ័យហេតុនេះ សហមេធាវីទាំងនេះមិនអាចលើកឡើងអះអាងដែលគួរឲ្យជឿបានថា ពួកខ្លួនត្រូវបានបដិសេធនៅដំណាក់កាលណាមួយមិនឲ្យមានពេលវេលា ឬការបង្កលក្ខណៈងាយស្រួល សម្រាប់ឲ្យបំពេញមុខងាររបស់ពួកខ្លួនដោយពេញលេញ និងតាមសមត្ថភាពនោះឡើយ។

២១- ទីបី មេធាវីការពារក្តីបានលើកឡើងតវ៉ាអំពីវិធីសាស្ត្ររបស់អង្គជំនុំជម្រះក្នុងការកំណត់កាលបរិច្ឆេទសម្រាប់សាក្សី[39]។ ការលើកឡើងអះអាងនេះក៏មិនមានមូលដ្ឋានត្រឹមត្រូវដែរ ដោយបានទទួលនូវសំណូមពររបស់ភាគីនានាជាលាយលក្ខណ៍អក្សរ អង្គជំនុំជម្រះបានផ្តល់នូវសេចក្តីជូនដំណឹងជាមុនអំពីសាក្សីថា ខ្លួនមានបំណងនឹងធ្វើការកោះហៅសាក្សីនានា នៅក្នុងពេលណាមួយក្នុងរយៈពេលប្រាំខែមុនការចាប់ផ្តើមការជំនុំជម្រះក្តី។ បញ្ជីនេះជាបន្តបន្ទាប់មកត្រូវបានធ្វើការកែប្រែ នឹងដាក់បន្ថែមជាការជំនុំជម្រះក្តីដែលត្រូវបានលាតត្រដាង។ នៅក្នុងទូទាំងដំណើរការនីតិវិធី អង្គជំនុំជម្រះបានផ្តល់ជូននូវសេចក្តីជូនដំណឹងជាមុនដល់ភាគីនានាដូចជា ការកំណត់កាលបរិច្ឆេទនៃក្រុមរបស់សាក្សី (ដោយមានសេចក្តីជូនដំណឹងបន្ថែមសម្រាប់សាក្សីជាបុគ្គលដែលនៅក្នុងក្រុមថែមទៀត) ដែលការផ្លាស់ប្តូរកាលបរិច្ឆេទមានម្តងម្កាល ដោយសារកត្តានានាដែលហួសពីការគ្រប់គ្រងរបស់អង្គជំនុំជម្រះ ដូចជាការផ្គត់ផ្គង់ភស្តុភារ និងភាពដែលអាចមានពេលវេលាមកបានរបស់សាក្សី។ តាមកម្រិតដែលការផ្លាស់ប្តូរទាំងឡាយត្រូវបានធ្វើឡើងនោះ តាមការពិត គឺវាមានផលប៉ះពាល់ចំពោះសហព្រះរាជអាជ្ញាច្រើនជាងមេធាវីការពារក្តីឆ្ងាយណាស់។ ដោយសារ សហព្រះរាជអាជ្ញាត្រូវបានប្រគល់អំណាចឲ្យសួរដេញដោលលើភ័ស្តុតាងសំខាន់សម្រាប់គាំទ្ររាល់ការលើកឡើងដោយសាក្សី និងអ្នកជំនាញទាំងអស់ដែលមានបន្ទុកត្រូវបង្ហាញនៅក្នុងសវនាការ ដែលខ្លួនបានស្នើឡើងនៅក្នុងការជំនុំជម្រះក្តីនេះ។ មេធាវីការពារក្តីមានពេលវេលាបន្ថែម ដើម្បីត្រៀមរៀបចំសម្រាប់ការសួរដេញដោលរបស់ពួកគេហើយ។ តាមការពិត មេធាវីរបស់ ខៀវ សំផន មានពេលវេលាច្រើនជាងនេះ សម្រាប់ត្រៀមរៀបចំដើម្បីសួរដេញដោលសាក្សីជាងភាគីណាមួយ ពីព្រោះពួកគេជាតួយ៉ាងបានទទួលបន្ទុកក្នុងការសួរដេញ

---

[39] ឯកសារលេខ **E288/4** សេចក្តីជូនដំណឹងពីការដកខ្លួន, ត្រង់កថាខណ្ឌទី១៧។

ដោលចុងក្រោយគេបន្ទាប់ពីសហព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រម និងក្រុមមេធាវីការពារក្តីដទៃទៀត។ ការចោទប្រកាន់របស់មេធាវីការពារក្តីអំពីការគ្មានពេល ដើម្បីត្រៀមរៀបចំត្រូវបានបំភាន់បន្ថែមទៀតដោយសំណើមួយចំនួនរបស់ខ្លួនផ្ទាល់ ដែលសុំឲ្យសួរដេញដោលសាក្សីមួយចំនួននៅមុនក្រុមមេធាវីការពារក្តីដទៃៗទៀត។

២២- ទីបួន មេធាវីការពារក្តីលើកពីបញ្ហានៃការប្រើភ័ស្តុតាងពីសវនាការទីមួយនេះ នៅក្នុងសវនាការបន្តបន្ទាប់[40]។ គ្មានការពន្យល់ផ្នែកច្បាប់ត្រូវបានគេធ្វើឡើង អំពីរបៀបថាតើគោលជំហរផ្នែកច្បាប់នេះនឹងធ្វើឲ្យប៉ះពាល់ដល់ការសម្រេចចិត្តរបស់ជនជាប់ចោទ ទាក់ទិននឹងការផ្តល់សក្ខីកម្មនៅក្នុងសវនាការនេះឡើយ។ តាមពិតបញ្ហាទាំងពីរនេះមិនជាប់ទាក់ទងគ្នាទេ។ ក្នុងដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី ចេញក្នុងខែកញ្ញា ឆ្នាំ២០១១ ជនជាប់ចោទត្រូវបានគេជម្រាបឲ្យដឹងថា ភ័ស្តុតាងដែលបានស្តាប់ក្នុងសវនាការនេះ នឹងបង្កើតបានជាមូលដ្ឋានសម្រាប់សវនាការនាពេលអនាគត។ គាត់បានសាទរចំពោះដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីនេះ បន្ទាប់មកបាននិយាយក្នុងឱកាសជាច្រើនថា គាត់នឹងផ្តល់សក្ខីកម្ម ហើយជាចុងក្រោយគាត់ក៏បានផ្តល់សក្ខីកម្មមែនក្នុងឱកាសជាច្រើនក្នុងសវនាការ។ ការលើកឡើងរបស់មេធាវីការពារក្តីអំពីការប្រើភ័ស្តុតាង នៅក្នុងសវនាការនាពេលអនាគត ធ្វើជាមូលហេតុស្មានៗសម្រាប់ជាការប្រែក្រឡាស់ជាយុទ្ធសាស្ត្ររបស់ជនជាប់ចោទ ទាក់ទិននឹងផ្តល់សក្ខីកម្ម គឺគ្មានមូលដ្ឋានទាំងស្រុង។

២៣- ទីប្រាំ មេធាវីការពារក្តី និង ខៀវ សំផន តវ៉ាថា ការកម្រិតចំនួនទំព័រសម្រាប់ដាក់សារណាបិទការចោទប្រកាន់គឺវាខ្លីពេក[41]។ បញ្ហាអំពីការកម្រិតចំនួនទំព័រសម្រាប់ការដាក់សារណាបិទការចោទប្រកាន់នេះ ធ្លាប់ជាកម្មវត្ថុនៃការជជែកគ្នាយ៉ាងច្រើននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ហើយមេធាវីការពារក្តីធ្លាប់មានឱកាសច្រើនសន្ធឹកសន្ធាប់ដើម្បីថ្លឹងថ្លែងលើបញ្ហានេះ[42]។ លើសពីនេះ គេមិនអាចយកការទាមទារណាមួយថាជាការត្រឹមត្រូវ នៅពេលដែលគោលការណ៍ស្មើរភាពនៃសិទ្ធិអំណាចត្រូវបាន និងកំពុងសម្របសម្រួល ពេលដែលអនុបាតនៃចំនួនទំព័រកំណត់គឺ ១:១ រវាងសហសហព្រះ

[40] **E288/4** សេចក្តីជូនដំណឹងអំពីការដកខ្លួន, ត្រង់កថាខណ្ឌទី៣០។

[41] សេចក្តីព្រាងប្រតិចារឹក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី៤១។ **E288/4** សេចក្តីជូនដំណឹងអំពីការដកខ្លួន, ត្រង់កថាខណ្ឌទី៣៣-៣៤។

[42] *សូមមើល ឧទាហរណ៍* **E1/114.2** ប្រតិចារឹក ២៧ សីហា ២០១២ ត្រង់ទំព័រទី១២-២៩ (រួមទាំងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារក្តីចំពោះបញ្ហានេះ ត្រង់ទំព័រ២៦-២៩)។ **E163/5/4** អនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងស្តីពី៖ ការជូនដំណឹងបន្ថែមអំពីបែបបទនៃការដាក់សេចក្តីសន្និដ្ឋានបញ្ចប់ការពីភាគីរដេញដោល, ២៦ វិច្ឆិកា ២០១២។

រាជអាជ្ញា និងជនជាប់ចោទម្នាក់ៗនោះឡើយ។ ជាការបន្ថែម ដូចសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់នៅក្នុងតុលាការថា បើសិនជាមេធាវីការពារក្តីមានអារម្មណ៍ថា ខ្លួនត្រូវការពេលវេលា និងទំព័រច្រើនជាងនេះសម្រាប់ថ្លែងពីករណីរបស់ខ្លួន នោះការណ៍នេះនឹងបានជាសេចក្តីភ្ជាប់ចិត្តរបស់ខ្លួន មិនខាន និងក៏មិនប្រឆាំងនឹងភ័ស្តុតាងដែលគាត់បានផ្តល់ដែរ[43]។

២៤- ទីប្រាំមួយ មេធាវីការពារក្តីបានធ្វើបណ្តឹងជាច្រើនទាក់ទិននឹងការទទួលយកឯកសារ[44]។ នៅក្នុងតុលាការ សហព្រះរាជអាជ្ញាបានកត់សម្គាល់ពីប្រភេទនៃការសន្និដ្ឋានខុស និងភាន់ច្រឡំរបស់មេធាវីការពារក្តី[45]។ ការទទួលយកឯកសារ និងតម្លៃភស្តុតាងរបស់វា ក៏ធ្លាប់បានតវ៉ាយ៉ាងហ្មត់ចត់នៅចំពោះអង្គជំនុំជម្រះនេះផងដែរ ដោយមានឱកាសយ៉ាងច្រើនសម្រាប់មេធាវីការពារក្តី ក្នុងការធ្វើការសន្និដ្ឋាន និងការបង្ហាញ។ ពួកគេតែងតែមិនឆក់យកឱកាសទាំងនេះទេ ប៉ុន្តែនោះគឺជាជម្រើសរបស់ពួកគាត់។ តាមពិត ថ្មីៗនេះទៀតពួកគាត់ក៏ត្រូវបានផ្តល់ឱកាសមួយ ដើម្បីជម្រាបជូនអង្គជំនុំជម្រះសាលាដំបូង ដូចចៅក្រម Lavergne បានថ្លែងយ៉ាងដូច្នេះថា “តើឯកសារណាដែលខ្លួនកំពុងតវ៉ា ហើយលោកអាចប្រាប់យើងបានទេថា ពេលវេលាប៉ុន្មានដែលលោកត្រូវការសម្រាប់តវ៉ាចំពោះឯកសារដែលបានបង្ហាញ តើលោកអាចប្រាប់យើងពីគោលជំហររបស់លោកបានទេ? វាមិនមែនស្មុគស្មាញពេកទេ”[46]។ មេធាវីការពារក្តីមិនអាច ឬក៏មិនចង់ផ្តល់ចម្លើយចំពោះសំណួរដ៏សាមញ្ញនេះទេ។ ចៅក្រម Lavergne បានធ្វើការសង្កេតយ៉ាងសមរម្យថា មេធាវីការពារក្តី “បានចូលរួមនៅក្នុងសវនាការក្នុងពេលដែលឯកសារត្រូវបានបង្ហាញ ហើយលោកបានសង្កេតឃើញពីក្រុមដទៃទៀតបង្ហាញឯកសារ ហើយក៏តវ៉ាចំពោះឯកសារនោះតែម្តង”[47]។

២៥- ក្នុងពេលថ្មីៗបំផុតនេះ គឺថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ លោក Verken និងលោក គង់ សំអុន ខកខានមិនបានបង្ហាញឯកសារសំខាន់ៗ និងឆ្លើយតបទៅនឹងឯកសារសំខាន់ៗដែលបានបង្ហាញដោយសហព្រះរាជអាជ្ញាទេ។ លើសពីនេះ នៅពេលអង្គជំនុំជម្រះសួរ ដោយសារ កង្វះនៃការត្រៀមរៀបចំរហូតមកដល់ពេលនេះ ថាតើពួកគេចង់បានឱកាសមួយផ្សេងទៀតដើម្បីធ្វើការបង្ហាញ ឬទេ (និងពេលវេលា

[43] សេចក្តីព្រាងប្រតិចារិក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី៥៩។
[44] សេចក្តីព្រាងប្រតិចារិក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី៥៣-៥៥។
[45] សេចក្តីព្រាងប្រតិចារិក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី៥៨-៥៩។
[46] **E1/207.1** ប្រតិចារិក ១៣ មិថុនា ២០១៣ ត្រង់ទំព័រទី១៣។
[47] **E1/207.1** ប្រតិចារិក ១៣ មិថុនា ២០១៣ ត្រង់ទំព័រទី១៥។

ប៉ុន្មានដែលពួកគាត់ត្រូវការសម្រាប់ការត្រៀមរៀបចំ) ពួកគាត់គ្រាន់តែបដិសេធយ៉ាងសាមញ្ញមិនឆ្លើយតប ហេតុដូចនេះ គឺបានរំលងឱកាសមួយទៀតដែលបានផ្ដល់ឲ្យពួកគាត់សម្រាប់គោលបំណងនេះ។

២៦- ដូចសហព្រះរាជអាជ្ញាបានកត់សម្គាល់នៅក្នុងសវនាការ ការជំទាស់ដែលយឺតយ៉ាវនិងមានលក្ខណៈប្រតិសកម្មទាំងនេះដែលធ្វើឡើងដោយមេធាវីការពារក្ដី គឺមានតម្លៃស្មើនឹងអ្វីមួយដូចជាការលាក់ពុតទាំងស្រុងមួយដែរ។ មេធាវីការពារក្ដីកំពុងស្វែងរកអ្វីដែលជាតំណាងមិនត្រឹមត្រូវចំពោះកំណត់ហេតុនៃសវនាការនេះ ហើយបានបញ្ជូនភាគនៃបណ្ដឹងដែលគ្មានអង្គសេចក្ដីជាច្រើន ដើម្បីធ្វើជាយុត្តិកម្មចំពោះការសម្រេចចិត្តជាយុត្តិសាស្ត្ររបស់កូនក្ដីខ្លួន ដើម្បីដកខ្លួនចេញពីការផ្ដល់សក្ខីកម្ម។

### *គ. អង្គជំនុំជម្រះសាលាដំបូងគួរយកចិត្តទុកដាក់ចំពោះការទាញសេចក្ដីសន្និដ្ឋានអវិជ្ជមានពីភាពស្ងៀមស្ងាត់ចោះៗរបស់ ខៀវ សំផន*

២៧- នៅក្នុងសវនាការកាលពីថ្ងៃទី៩ ខែកក្កដា ឆ្នាំ២០១៣ សហព្រះរាជអាជ្ញាបានរំលឹកពីការព្រមានរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ដែលបានដាក់ជនជាប់ចោទក្នុងប្រវេសន៍នៃសេចក្ដីសន្និដ្ឋានអវិជ្ជមានដែលអាចទាញយកពីការបដិសេធចោះៗ ក្នុងការឆ្លើយទៅនឹងសំណួរផ្សេងៗ។ សហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ថា ដោយសារបានផ្ដល់ការព្រមាននេះ ខៀវ សំផន ក៏បានផ្ដល់ភ័ស្ដុតាងនៅក្នុងរយៈពេលនៃដំណើរការសវនាការ ដូច្នេះនេះជាការលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបដោយគ្មានមន្ទិល។ ជាចុងក្រោយពួកគាត់បានថ្លែងថា សេចក្ដីសន្និដ្ឋានអវិជ្ជមានគួរតែទាញយកពីសេចក្ដីពិចារណាលើភ័ស្ដុតាងរបស់អង្គជំនុំជម្រះ បើសិនជាជនជាប់ចោទនៅតែប្រកាន់ជំហររបស់ម៉ាត់ ចំពោះការសម្រេចចិត្តបដិសេធមិនឆ្លើយនឹងសំណួរផ្សេងៗ”[48]។ ចៅក្រម Lavergne ក៏បានបញ្ជាក់ពីផលវិបាកនេះដល់មេធាវីការពារក្ដីដោយបានថ្លែងថា “ខ្ញុំក៏ជឿថាក្រុមមេធាវីការពារក្ដីបានស្ដាប់ ឮសំណើរបស់សហព្រះរាជអាជ្ញាហើយ ដែលមានទាំងការនៅប្រកាន់យកតាមការសម្រេចរបស់អង្គជំនុំជម្រះ ចំពោះផលវិបាកដែលអាចកើតមានចំពោះការបដិសេធមិនឆ្លើយនឹងសំណួរផ្សេងៗ នៅក្នុងដំណាក់កាលជាក់លាក់នៃកិច្ចដំណើរការនីតិវិធីនេះ”[49]។ មេធាវីការពារក្ដីមិនបានជំទាស់ ឬឆ្លើយតបទៅនឹងការព្រមាននេះទេ។

[48] សេចក្ដីព្រាងប្រតិចារឹក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី២៩, ៣៣-៣៥។

[49] សេចក្ដីព្រាងប្រតិចារឹក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី៤២។

២៨- គេមិនមានបញ្ហាចំពោះ ខៀវ សំផន ដែលបានលះបង់សិទ្ធិនៅស្ងៀមមិនឆ្លើយតបទេ។ គាត់បានផ្តល់ភ័ស្តុតាងនៅក្នុងឱកាសជាច្រើនតាមរយៈការធ្វើសេចក្តីថ្លែង និងការឆ្លើយនឹងសំណួរផ្សេងៗរបស់ដើមបណ្តឹងរដ្ឋប្បវេណី[50] ខណៈជាមួយគ្នានោះក៏មានការធានាចំពោះអង្គជំនុំជម្រះ និងភាគីថា គាត់មានបំណងនឹងផ្តល់សក្ខីកម្ម[51]។ ដូចអង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY បានសម្រេចយ៉ាងដូច្នេះថា"នៅពេលជនជាប់ចោទបានសម្រេចចិត្តធ្វើជាសាក្សី គាត់ត្រូវមានកាតព្វកិច្ចឆ្លើយទៅនឹងសំណួរផ្សេងៗ ទោះបីជាចម្លើយអាចដាក់ពិរុទ្ធលើខ្លួនឯងក៏ដោយ"[52]។ ខៀវ សំផន បានជ្រើសរើសយកការផ្តល់ភ័ស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ ហើយការដែលបានធ្វើដូច្នេះ គឺគាត់មិនមានសិទ្ធិបដិសេធមិនឆ្លើយនឹងសំណួរផ្សេងៗពីភាគី និងអង្គជំនុំជម្រះដោយគ្មានផលវិបាកនោះឡើយ។ ការព្រមានរបស់អង្គជំនុំជម្រះនេះ ចំពោះភាពជាប់ជំពាក់វាក់វិននៃគោលការណ៍នេះ គឺច្បាស់លាស់៖

> នៅក្នុងការវាយតម្លៃអំពីពិរុទ្ធភាព ឬភាពគ្មានទោសរបស់ជនជាប់ចោទនៅក្នុងសាលក្រមរបស់ខ្លួន អង្គជំនុំជម្រះត្រូវពិចារណាលើគ្រប់ភ័ស្តុតាងទាំងអស់ដែលបានដាក់នៅចំពោះមុខខ្លួន ហើយដែលត្រូវស្ថិតនៅក្រោមការសួរដេញដោល រួមទាំងសក្ខីកម្មរបស់ជនជាប់ចោទផង ព្រមទាំងពីរបៀបដែលគាត់បានផ្តល់សក្ខីកម្មនោះ។ ទាក់ទិននឹងចំណុចនេះ ហើយបើសិនជាជនជាប់ចោទជ្រើសយកជម្រើសឆ្លាស់គ្នារវាងការនៅស្ងៀមមិនឆ្លើយតប និងការផ្តល់សក្ខីកម្ម ការណ៍នេះអាចនឹងត្រូវបានធ្វើការកត់សម្គាល់ដោយអង្គជំនុំជម្រះនៅពេលវាយតម្លៃលើភាពជឿជាក់។ យុត្តិសាស្ត្រអន្តរជាតិដែលពាក់ព័ន្ធបង្ហាញថា សេចក្តីសន្និដ្ឋានអវិជ្ជមានដែលទាញចេញពីសេចក្តីសម្រេចធ្វើឡើង ដោយចោះៗចំពោះភាពនៅស្ងៀមមិនឆ្លើយតប អាចត្រូវធ្វើឡើងបាន[53]។

---

[50] **E1/21.1** ប្រតិចារឹក ១៣ ធ្នូ ២០១១ ត្រង់ទំព័រទី៥៩។ **E1/21.1** ប្រតិចារឹក ១៣ ធ្នូ ២០១១ ត្រង់ទំព័រទី៧០-៨០។ **E1/26.1** ប្រតិចារឹក ១២ មករា ២០១២ ត្រង់ទំព័រទី៥៦, ៦៧។ **E1/196.1** ប្រតិចារឹក ២៣ ឧសភា ២០១៣ ត្រង់ទំព័រទី១៧-១៨។ ។ **E1/197.1** ប្រតិចារឹក, ២៧ ឧសភា ២០១៣, ត្រង់ទំព័រទី២១-២៣, ៨២-៨៥, **E1/198.1** ប្រតិចារឹក, ២៩ ឧសភា ២០១៣, ត្រង់ទំព័រទី១៨-២៤, ៩, ៥៤-៥៥, ៨៥-៨៩, **E1/199.1** ប្រតិចារឹក, ៣០ ឧសភា ២០១៣, ត្រង់ទំព័រទី១៦-១៨, ៨០-៨៣, **E1/200.1** ប្រតិចារឹក, ៤ ខែមិថុនា ២០១៣, ត្រង់ទំព័រទី២៤-២៥, ៦៨-៧០, ១០៩-១១០។ *សូមមើលជាទូទៅ ឯកសារ* E174។

[51] **E1/15.1** ប្រតិចារឹក ២៣ វិច្ឆិកា ២០១១ ត្រង់ទំព័រទី១៧-១៨, ៤៨។ **E1/21.1** ប្រតិចារឹក ១៣ ធ្នូ ២០១១ ត្រង់ទំព័រទី៦៧-៦៩។ **E1/26.1** ប្រតិចារឹក ១២ មករា ២០១២ ត្រង់ទំព័រទី៨០។ *សូមមើលជាទូទៅ* **E174** សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឱ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយតបទៅនឹងសំណួរនៅក្នុងសវនាការ, ១៧ កុម្ភៈ ២០១២។

[52] *រដ្ឋអាជ្ញា ទល់នឹង Gotovina និងគូកន.*, IT-06-90-T, សេចក្តីសម្រេចលើញត្តិរួមរបស់មេធាវីការពារក្តី សុំឱ្យហាមឃាត់ការប្រើប្រាស់ឯកសាររបស់មេធាវីការពារក្តីដោយអយ្យការ, ៥ ធ្នូ ២០០៨, ត្រង់កថាខណ្ឌទី៩។

[53] **E1/63.1** ប្រតិចារឹក ១៨ មេសា ២០១២ ត្រង់ទំព័រទី១១.១២.៣២។

២៩- ដូចបានកត់សម្គាល់ដោយសហព្រះរាជអាជ្ញា ការអនុវត្តគោលការណ៍នេះ គឺដើម្បីថែរក្សាភាពស្រប គ្នាទៅនឹងយុត្តិសាស្ត្រអន្តរជាតិ[54]។ តុលាការ ICTY បានសម្រេចថា បើសិនជាជនជាប់ចោទបានផ្តល់ សក្ខីកម្មដោយចោះៗ សំណួរទាំងឡាយដែលគាត់បដិសេធមិនឆ្លើយអាចនឹងនាំឲ្យមាន "ការពិចារណា ដែលមានលក្ខណៈពេញចិត្តតិចតួច អំពីទិដ្ឋភាពនៃសក្ខីកម្មនោះ ដោយអង្គជំនុំជម្រះសាលាដំបូង នៅ ពេលអង្គជំនុំជម្រះនេះធ្វើការវាយតម្លៃចំពោះសក្ខីកម្មនោះ"[55]។

៣០- ជម្រើសរបស់ ខៀវ សំផន ដើម្បីផ្តល់តែសក្ខីកម្មចោះៗ និងមិនឆ្លើយនឹងសំណួរផ្សេងៗ គួរតែមាន ផលវិបាកពីរ៖ ក) សក្ខីកម្មផ្ទាល់មាត់របស់គាត់នៅចំពោះមុខអង្គជំនុំជម្រះ គួរតែទទួលបានទម្ងន់តិច តួច រហូតដល់គ្មានទម្ងន់សោះ[56] និង ខ) សេចក្តីសន្និដ្ឋានអវិជ្ជមាន គួរបានធ្វើឡើងនៅក្នុងសេចក្តី ពិចារណាលើភ័ស្តុតាងប្រឆាំងនឹងខ្លួនគាត់[57]។ ទាក់ទងនឹងផលវិបាកចុងក្រោយនេះ សហព្រះរាជអាជ្ញា ស្នើសុំឱកាសដើម្បីថ្លែងនៅក្នុងតុលាការដោយមានវត្តមានរបស់ ខៀវ សំផន ពីប្រធានបទ និង អង្គហេតុដែលសហព្រះរាជអាជ្ញានឹងសួរគាត់ និងដែលនឹងស្នើឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ចំពោះ ការទាញយកការសន្និដ្ឋានអវិជ្ជមាន នៅក្នុងសារណាបិទសវនាការចុងក្រោយរបស់ខ្លួន។

## III. សំណើ

៣១- ដូចមូលហេតុជម្រាបជូនខាងលើ សហព្រះរាជអាជ្ញាសូមស្នើឲ្យអង្គជំនុំជម្រះសាលាដំបូង៖

ក. **ច្រានចោល** ដោយសារគ្មានមូលដ្ឋាន ចំពោះសម្អាងហេតុអះអាងដោយមេធាវីការពារក្តី សម្រាប់ការដកខ្លួនចេញរបស់ ខៀវ សំផន ពីការផ្តល់សក្ខីកម្ម។

[54] សេចក្តីព្រាងប្រតិចារឹក ៩ កក្កដា ២០១៣ ត្រង់ទំព័រទី៣៣-៣៤។

[55] *រដ្ឋអាជ្ញា ទល់នឹង Blagojević និង Jokić,* សេចក្តីសម្រេចលើសំណើផ្ទាល់មាត់របស់ Vidoje Blagojević, ៣០ កក្កដា ២០០៤ ត្រង់ ទំព័រទី៧។

[56] *សូមមើល* **E174** សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធ មិនឆ្លើយតបទៅនឹងសំណួរនៅក្នុងសវនាការ, ១៧ កុម្ភៈ ២០១២, កថាខណ្ឌទី១៦-២០។

[57] **E174** សំណើរបស់សហព្រះរាជអាជ្ញា ដើម្បីសុំឲ្យជូនដំណឹងដល់ជនជាប់ចោទ ខៀវ សំផន ស្តីពីផលវិបាកនានានៃការបដិសេធមិនឆ្លើយ តបទៅនឹងសំណួរនៅក្នុងសវនាការ, ១៧ កុម្ភៈ ២០១២, កថាខណ្ឌទី២១-២៥។

ខ. **បញ្ជាក់អះអាង** ថាបើសិនជា ខៀវ សំផន នៅតែបដិសេធមិនឲ្យមានការសួរដេញដោល អង្គជំនុំជម្រះនេះនឹងពិចារណាលើចម្លើយទាំងអស់ដែលគាត់បានផ្តល់ ឬនឹងផ្តល់ ស្របទៅតាមស្មារតីនៃការពិតនោះ ហើយនឹងទាញយកការពិចារណាផ្ទុយប្រឆាំងនឹងខ្លួនគាត់នៅក្នុងសេចក្តីពិចារណាលើភស្តុតាងរបស់ខ្លួន នៅក្នុងពេលពិភាក្សាសម្រេច និង

គ. **អនុញ្ញាតផ្តល់ជូន** សហព្រះរាជអាជ្ញានូវឱកាសមួយ ដើម្បីបង្ហាញ ដោយមានវត្តមានរបស់ជនជាប់ចោទ និងនៅមុនពេលបិទកិច្ចដំណើរការនីតិវិធីលើភស្តុតាង នូវប្រធានបទ និងអង្គហេតុនានាដែលសហព្រះរាជអាជ្ញានឹងសួរ ខៀវ សំផន និងដែលសហព្រះរាជអាជ្ញានឹងស្នើសុំឲ្យអង្គជំនុំជម្រះយកចិត្តទុកដាក់ចំពោះការទាញយកការពិចារណាអវិជ្ជមាន៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៣ | **លោកស្រី ជា លាង** សហព្រះរាជអាជ្ញា | ភ្នំពេញ | |
| | **លោក** Andrew CAYLEY សហព្រះរាជអាជ្ញា | | |